KO 3309
TSL BOX4

# ករណី ឈាង

អាយុ ២៩ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

- អតីតៈកម្មករ រោងចក្រកង់ឡាន តាខ្មៅ ។

• បច្ចុប្បន្ន : កម្មករ "ក១" ។

១៩៦៧ • ចូលធ្វើការនៅរោងចក្រកង់ឡាន តាខ្មៅ ។ បានទាក់ទងជិតស្និត ឃឹម អុល - សេ ៧២ បច្ចុប្បន្នៈ ក១ - អ៊ុំ ស៊ីនឿន និង ព្រុំ ប៊ុនជិន - បុគ្គលិករោងចក្រកង់ឡាន តាខ្មៅ និង សេអ៊ីអា បច្ចុប្បន្នៈមិនដឹង - ហើយបានទទួលការអប់រំឱ្យស្អប់កុម្មុយនីស្ត ស្អប់ខ្មែរក្រហម រហូតមក ។

១៩៧២ • ចូល សេ អ៊ី អា នៅរោងចក្រ កង់ឡាន តា ខ្មៅ ។

អ្នកនាំចូល ព្រុំ ប៊ុនជិន និង អ៊ុំ ស៊ីនឿន

ទទួលស្គាល់ ពិន ថុន - បច្ចុប្បន្ន : ចាប់ខ្លួន -

ប្រាក់ខែ ២៥.០០០ រៀល

ភារកិច្ច ឃោសនា ប្រឆាំងកុម្មុយនីស្ត និងខ្មែរក្រហម ស៊ើបរកការ ជ្រៀតចូលកងទ័ពបដិវត្តនៅខាងត្បូងក្រុង តាខ្មៅ ។

សកម្មភាព : ក្រោយ ១៧.៤.៧៥ :

ធ្វើសកម្មភាព សេ អ៊ី អា ប្រឆាំងបដិវត្តក្នុងក្រុម តែម សុផុន ។

- បានរួមឃោសនាបំផុសបំផុល កម្មករចាស់ឱ្យប្រឆាំងបដិវត្ត លើកបញ្ហាស៊ីចុកដែលមិនស្មើភាព វាយប្រហារកម្មាភិបាលដឹកនាំ ថាត្រួតត្រាមើលតែចៅហ្វាយនាយសង្គមមុន ថាបណ្ដាច់បណ្ដោច កុមារពីឪពុកម្ដាយ ថាប្រើកម្មករ មើលតែសត្វ ។

៩.៧៥ • ដំឡើងម៉ាស៊ីនមួយគ្រឿងឱ្យខុស ដើម្បីបង្អាក់ដំណើរការរោងចក្រ ។

- ពេលក្រោយពុមកទៀត កាលណាមានការត្រូវជួសជុលម៉ាស៊ីន ច្រើនធ្វើពុតជាឈឺ ។

៚